ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ ៧ ឆ្នាំ២០០៣

# សារាចរ

## ស្តីពី

## ការហាមលក់ឱសថក្លែងក្លាយ

អនុលោមតាម ច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងដោយពិនិត្យឃើញថា បច្ចុប្បន្ននេះនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា មានការលក់នូវឱសថផលិតក្នុងស្រុក និងឱសថនាំចូលខុសច្បាប់មួយចំនួន ដែលពុំបានចុះលេខទិដ្ឋាការ-បញ្ជិកា នៅក្រសួងសុខាភិបាល និង ដើម្បីទប់ស្កាត់ការលក់ឱសថប្រភេទខាងលើ ក្រសួងសុខាភិបាលមានវិធានការណែនាំដូចតទៅ :

១-ត្រូវបានចាត់ទុកជាឱសថក្លែងក្លាយ ឱសថទាំងឡាយណាដែល :

-ផលិតខុសសារធាតុសកម្មដោយចេតនា

-ផលិតដោយចេតនា គ្មានសារធាតុសកម្ម ឬមានកំរិតសារធាតុសកម្មមិនត្រឹមត្រូវតាមស្តង់ដារ ដែលមានចែងក្នុងហ្វាម៉ាកូប៉េ ទទួលស្គាល់ពីក្រសួងសុខាភិបាល ។

-បន្លំដោយចេតនា លើផ្លាកសញ្ញានូវប្រភព និងអត្តសញ្ញាណ នៃឱសថមួយទៀតដែលជាឱសថពិត ។

-វេចខ្ចប់ ឬផលិតដោយបុគ្គលគ្មានអាជ្ញាប័ណ្ណពីក្រសួងសុខាភិបាល ។

២-បុគ្គលដែលលក់ឱសថក្លែងក្លាយ ត្រូវផ្តន្ទាទោសតាមទោសបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងឱសថ ។ ឱសថក្លែងក្លាយដែលពាក់ព័ន្ធនឹងបទល្មើស ត្រូវឃាត់ទុក បំផ្លាញចោល និងផ្សព្វផ្សាយជាសាធារណៈ ។

៣-ដើម្បីជៀសវាងការចោទប្រកាន់ពីការជួញដូរឱសថក្លែងក្លាយ :

-ឱសថស្ថាន-ឱសថស្ថានរងទាំងអស់ត្រូវទិញឱសថពីគ្រឹះស្ថានផលិតឱសថ ឬគ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ ដែលមានអាជ្ញាប័ណ្ណពីក្រសួងសុខាភិបាល និងមានវិក័យប័ត្របញ្ជាញលក់ត្រឹមត្រូវពីគ្រឹះស្ថានទាំងនោះ ។

-គ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថទាំងអស់ ត្រូវនាំចូលតែឱសថដែលបានចុះលេខបញ្ជិកា និង មានវិញ្ញាបនប័ត្រ វិភាគបញ្ជាក់គុណភាពត្រឹមត្រូវ និងចែកចាយតែឱសថដែលមានបិទលតប័ត្របញ្ជាក់ឈ្មោះក្រុមហ៊ុននាំចូល និង លេខបញ្ជិកា របស់ក្រសួងសុខាភិបាល ។

-គ្រឹះស្ថានផលិតឱសថ ត្រូវចែកចាយតែឱសថ ដែលបានចុះលេខទិដ្ឋាការ ពីក្រសួងសុខាភិបាល ។

-គ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ និងគ្រឹះស្ថានផលិតឱសថ ត្រូវចេញវិក័យប័ត្រលក់ ដែលមានបញ្ជាក់ឈ្មោះ និងអាស័យដ្ឋានត្រឹមត្រូវ គ្រប់រាល់ការចែកចាយឱសថ ។

ក្រសួងសង្ឃឹមថាអស់លោក-លោកស្រី ជាឱសថការីទទួលខុសត្រូវបច្ចេកទេស និងជាម្ចាស់ទុនគ្រឹះស្ថានឱសថទាំងអស់នឹងខិតខំយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើជាមិនខាន ដោយឈរលើស្មារតីទទួលខុសត្រូវចំពោះសុខភាពជូនប្រជាពលរដ្ឋអ្នកប្រើប្រាស់ ។

វេជ្ជ. ហុង - ស៊ុនហួត

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី (ដើម្បីជ្រាបជាពត៌មាន)

-ក្រសួងពត៌មាន (ដើម្បីជួយផ្សព្វផ្សាយ)

-នាយកដ្ឋាន ឱសថ-ចំណីអាហារ-បរិក្ខារពេទ្យ និងគ្រឿងសំអាង

-មន្ទីរសុខាភិបាលរាជធានី និងខេត្ត-ក្រុង

-គ្រឹះស្ថានផលិតឱសថ

-គ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ

-គ្រប់ឱសថស្ថាន-ឱសថស្ថានរង

(ដើម្បីអនុវត្តន៍)

-កាលប្បវត្តិ - ឯកសារ